# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ ២០១៣

**ឯកសារបកប្រែ**
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 06-May-2013, 14:50
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

## ចម្លើយតបទៅនឹងសំណើសុំរបស់សហព្រះរាជអាជ្ញាដែលស្នើឲ្យមានការដាក់បញ្ចូលសារទូរលេខ តាមផ្លូវទូតរបស់សហរដ្ឋអាមេរិកទៅក្នុងសំណុំរឿង

---

<u>ដាក់ដោយ</u>៖

**មេធាវីការពារក្ដីលោក ខៀវ សំផន**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

មេធាវី Arthur VERCKEN

មេធាវី Jacques VERGÈS

<u>ដាក់ជូន</u>៖

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យូរ ឧត្ដារា

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

**ជំនួយការ៖**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

កញ្ញា Shéhérazade BOUARFA

កញ្ញា Mathilde CHIFFERT

កញ្ញា Vera MANUELLO

កញ្ញា អ៊ូច ស្រីផាត់

កញ្ញា សុគន្ធ ម៉ូនីកា

លោក Pierre TOUCHE

កញ្ញា Blandine ZELLER

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Andrew CAYLEY

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

**ក្រុមមេធាវីការពារក្តីទាំងអស់**

# គោរពជូនអង្គជំនុំជម្រះសាលាដំបូង

## ១. សេចក្តីផ្តើម

១. កាលពីថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៣ សហព្រះរាជអាជ្ញាបានស្នើសុំការអនុញ្ញាតពីអង្គជំនុំជម្រះសាលាដំបូង ដើម្បីដាក់បញ្ចូលទៅក្នុងសំណុំរឿង និងទៅក្នុងកិច្ចពិភាក្សាដេញដោល នូវឯកសារសារទូរលេខតាមផ្លូវទូតរបស់ស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅទីក្រុងភ្នំពេញ ស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅប្រទេសឡាវ និងរបស់រដ្ឋមន្ត្រីការបរទេសសហរដ្ឋអាមេរិក ដែលបានផ្ញើចេញពីឆ្នាំ ១៩៧៣ ដល់ឆ្នាំ ១៩៧៥[1]។

២. សហព្រះរាជអាជ្ញាបានលើកឡើងថា នៅក្នុងសារទូរលេខតាមផ្លូវទូតទាំង ២៦ នោះ មានព័ត៌មានផ្សេងៗដែលជាប់ទាក់ទងដោយផ្ទាល់ទៅនឹងការជម្លៀសប្រជាជនចេញដោយបង្ខំ ការធ្វើទុក្ខបុកម្នេញលើប្រជាជនដែលរស់នៅទីក្រុង និងទីប្រជុំជននានាដូចខ្មាំងសត្រូវ និងការកាប់សម្លាប់ពួកទាហាន ព្រមទាំងមន្ត្រីទាំងឡាយនៃរបបសាធារណរដ្ឋខ្មែរ[2]។

៣. តាមរយៈចម្លើយតបនេះ ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន សូមធ្វើការប្រឆាំងទៅនឹងការទទួលយកទាំងស្រុងនូវឯកសារសារទូរលេខតាមផ្លូវទូតនេះ។

## ២. សារទូរលេខតាមផ្លូវទូតដែលពុំសមស្របសំរាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង

---

[1] សំណើរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ស្តីពីសារទូរលេខតាមផ្លូវទូតរបស់សហរដ្ឋអាមេរិក ដែលទើបតែអាចរកបាននាពេលថ្មីៗនេះ ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ E282 (តទៅនេះ ហៅថា "សំណើ") កថាខណ្ឌ ១ កថាខណ្ឌ ១៣ [ជូនដំណឹងជាភាសាអង់គ្លេស និងភាសាខ្មែរ នៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៣ និងជាភាសាបារាំង នៅថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣]។

[2] សំណើ កថាខណ្ឌ ១ កថាខណ្ឌ ៧។

៤. មេធាវីការពារក្ដីយល់ឃើញថា សារទូរលេខតាមផ្លូវទូតដែលបានលើកឡើងអំពីការវាយប្រយុទ្ធតាមផ្លូវយោធា ដែលកើតមានឡើងពីឆ្នាំ ១៩៧៣ ដល់ឆ្នាំ ១៩៧៥ ពុំមានមូលដ្ឋានជាក់ស្ដែងណាមួយឡើយ ហើយមិនមានភាពសមស្របសំរាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្ដុតាង ដូចដែលបានចែងដោយវិធាន ៨៧-៣-គ។

៥. បើតាមការលើកឡើងរបស់សហព្រះរាជអាជ្ញា សារទូរលេខតាមផ្លូវទូតមួយចំនួនបានពិពណ៌នាអំពីការវាយប្រហារធ្វើឡើងដោយកងកម្លាំងនៃបក្សកុម្មុយនីស្ដកម្ពុជា (បកក) ទៅលើទីក្រុង និងទីប្រជុំជននានា និងបានបង្ហាញភ័ស្ដុតាងនៃការប្រព្រឹត្តអំពើសាហាវយង់ឃ្នងពីសំណាក់កងកម្លាំងទាំងនោះទៅលើពួកទាហាន និងប្រជាជនស៊ីវិលនៅតាមទីក្រុង និងទីប្រជុំជននានាក្នុងប្រទេសកម្ពុជាពីឆ្នាំ ១៩៧៣ ដល់ឆ្នាំ ១៩៧៥[3]។

៦. មេធាវីការពារក្ដីជឿជាក់ថា ព័ត៌មានទាំងឡាយដែលទទួលបានពីសារទូរលេខតាមផ្លូវទូតទាំងនោះពុំមែនបានមកអំពីការវិភាគដោយឯករាជ្យទៅលើសភាពការណ៍ ដែលបានកើតឡើងពីចន្លោះឆ្នាំ ១៩៧៣ ដល់ ១៩៧៥ ឡើយ។

៧. សារទូរលេខតាមផ្លូវទូតទាំងអស់ លើកលែងតែសារទូរលេខមួយចេញ[4] ត្រូវបានតាក់តែងដោយស្ថានទូតអាមេរិកនៅភ្នំពេញ និងដោយក្រសួងការបរទេសអាមេរិក នៅក្នុងបរិបទនៃជម្លោះប្រដាប់អាវុធ ដែលសហរដ្ឋអាមេរិកខ្លួនឯងបានចូលរួមយ៉ាងជ្រៅជាមួយកងកម្លាំងសាធារណរដ្ឋខ្មែរ។ សារទូរលេខទាំងនោះស្ទើរតែទាំងអស់ ត្រូវបានផ្ញើទៅកាន់អង្គភាពយោធារបស់សហរដ្ឋអាមេរិកតួយ៉ាងដូចជា "អគ្គមេបញ្ជាការប្រចាំនៅប៉ាស៊ីហ្វិក" [5] "ក្រសួងការពារជាតិ"[6] "នាយអគ្គសេនា

---

[3] សំណើ កថាខណ្ឌ ៨។

[4] ឯកសារ **E282.1.14**។

[5] សូមមើលសារទូរលេខ៖ ឯកសារ **E282.1.1**, **E282.1.2**, **E282.1.4**, **E282.1.5**, **E282.1.6**, **E282.1.8**, **E282.1.9**, **E282.1.12**, **E282.1.13**, **E282.1.14**, **E282.1.15**, **E282.1.16**, **E282.1.17**, **E282.1.19**, **E282.1.21**, **E282.1.24**។

[6] សូមមើលសារទូរលេខ៖ ឯកសារ **E282.1.1**, **E282.1.2**, **E282.1.4**, **E282.1.21** ។

ធិការកងទ័ពអាមេរិក"[7] "មេបញ្ជាការក្រុមទីប្រឹក្សាពិសេសយោធាសហរដ្ឋអាមេរិក"[8] "ទីភ្នាក់ងារស៊ើបការសម្ងាត់យោធា"[9] "អគ្គមេបញ្ជាការកងនាវាអាមេរិកប្រចាំនៅប៉ាស៊ីហ្វិក"[10] ឬ "អគ្គមេបញ្ជាការកងទ័ពអាមេរិកប្រចាំនៅប៉ាស៊ីហ្វិក"[11] ។

៨. ពាក្យពេចន៍ និងវាក្យស័ព្ទដែលប្រើក្នុងសារទូរលេខទាំងនោះគឺ ជាពាក្យពេចន៍ និងវាក្យស័ព្ទដែលមានលក្ខណៈលម្អៀងទៅរកសហរដ្ឋអាមេរិក ពាក់ព័ន្ធនឹងការវាយប្រហារប្រដាប់អាវុធដែលកើតមានឡើងពីឆ្នាំ ១៩៧៣ ដល់ឆ្នាំ ១៩៧៥ រវាងកងទ័ពបក្សកុម្មុយនីស្តកម្ពុជា និងកងទ័ពសាធារណរដ្ឋខ្មែរ។ សារទូរលេខនោះភាគច្រើនបានចាត់ទុកកងទ័ពបក្សកុម្មុយនីស្តកម្ពុជាថាជា "ខ្មាំងសត្រូវ"[12] ចំណុចនេះបង្ហាញឲ្យឃើញថា ព័ត៌មានដែលផ្តល់តាមរយៈសារទូរលេខទាំងនោះមានលក្ខណៈលម្អៀង។ សារទូរលេខមួយចំនួនបានលើកឡើងអំពី "អំពើព្រៃផ្សៃនានា"[13] ដែលប្រព្រឹត្តឡើងដោយកងទ័ពសាធារណរដ្ឋខ្មែរ។ សារទូរលេខមួយចំនួនទៀត មានរហូតដល់ទៅជាការផ្តល់ប្រឹក្សាដល់កងទ័ពសាធារណរដ្ឋខ្មែរ ដើម្បីឲ្យពួកគេបង្កើនប្រសិទ្ធិភាពនៃការវាយលុកនាពេលអនាគត[14]។ ចំណុចនេះក៏បង្ហាញឲ្យឃើញផងដែរថា សហរដ្ឋអាមេរិកពិតជាបានចូលរួមក្នុងប្រតិបត្តិការសឹកជាមួយកងកម្លាំងសាធារណរដ្ឋខ្មែរមែន។

---

[7] សូមមើលសារទូរលេខ៖ ឯកសារ **E282.1.2**, **E282.1.4**, **E282.1.21** ។

[8] សូមមើលសារទូរលេខ៖ ឯកសារ **E282.1.2**, **E282.1.4**, **E282.1.5**, **E282.1.6**, **E282.1.8** ។

[9] សូមមើលសារទូរលេខ៖ ឯកសារ **E282.1.9**, **E282.1.15** ។

[10] សូមមើលសារទូរលេខ៖ ឯកសារ **E282.1.9**, **E282.1.12**, **E282.1.13**, **E282.1.15**, **E282.1.16**, **E282.1.19** ។

[11] សូមមើលសារទូរលេខ៖ ឯកសារ **E282.1.9**, **E282.1.15** ។

[12] ឧទាហរណ៍ សូមមើល៖ ឯកសារ **E282.1.1** កថាខណ្ឌ ១ *"ការតស៊ូរបស់ខ្មាំង"*, កថាខណ្ឌ ៤ *"កងកាំភ្លើងធំរបស់ខ្មាំង"* *"ការវាយប្រហាររបស់ខ្មាំង"* *"ការបាញ់ប្រហាររបស់ខ្មាំង"*, ឯកសារ **E282.1.2** កថាខណ្ឌ ២ *"ចិត្តសាស្ត្ររបស់ខ្មាំង"* កថាខណ្ឌ ៣ *"ខ្មាំង"*, ឯកសារ **E282.1.5** កថាខណ្ឌ ១ *"ខ្មាំង"*, ឯកសារ **E282.1.8** *"គ្រាប់កាំភ្លើងរបស់ខ្មាំង"*, ឯកសារ **E282.1.22** កថាខណ្ឌ ១ *"ខ្មាំង"*, ឯកសារ **E282.1.25** កថាខណ្ឌ ១ *"កងកម្លាំងរបស់ខ្មាំង"*។

[13] ឧទាហរណ៍ សូមមើល៖ ឯកសារ **E282.1.1**, **E282.1.9**, **E282.1.22**, **E282.1.25**.

[14] ឧទាហរណ៍ សូមមើល៖ ឯកសារ **E282.1.2** កថាខណ្ឌ ៣ "ស្ថានទូតសហរដ្ឋអាមេរិកណែនាំឲ្យកងទ័ពសាធារណរដ្ឋខ្មែររៀបចំបង្កើតកម្មវិធីជ្រើសរើសទាហានរឹងមាំមួយ ដើម្បីឲ្យការវាយប្រហារប្រដាប់អាវុធនាពេលខាងមុខទទួលបានលទ្ធផលកាន់តែប្រសើរ"។

៩. ភាពលម្អៀងនៃព័ត៌មាននានាដែលផ្ដល់តាមរយៈសារទូរលេខទាំងនោះ មានលក្ខណៈកាន់តែជាក់ច្បាស់ ជាពិសេសសារទូរលេខមួយ ដែលតាមរយៈនោះ សហរដ្ឋអាមេរិកបានស្នើទៅរដ្ឋាភិបាលសាធារណរដ្ឋខ្មែរឲ្យប្រើប្រាស់ព័ត៌មាននានាពាក់ព័ន្ធនឹងការវាយប្រយុទ្ធ ប្រឆាំងទៅនឹងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដើម្បីធ្វើឲ្យថមថយដល់កិត្តិនាមរបស់ចលនានេះនៅលើឆាកអន្តរជាតិ[15]។

១០. នៅក្នុងក្របខណ្ឌនៃជម្លោះប្រដាប់អាវុធដែលគេបានដឹងឮសុះសាយ ភាពលម្អៀងនៃព័ត៌មានដែលផ្ដល់ដោយសារទូរលេខផ្លូវទូតទាំងនេះ មិនបានផ្ដល់នូវអត្ថប្រយោជន៍អ្វីដល់កិច្ចពិភាក្សាឡើយ។ ជាក់ស្ដែង សារទូរលេខដែលផ្ញើចេញពីភាគីដែលជាអ្នកចូលរួមយ៉ាងសកម្មទៅក្នុងជម្លោះ ពិតជាពុំបានលើកឡើងអំពីប្រជាជនដែលទទួលរងរបួស និងសម្លាប់ដោយកងទ័ពសាធារណរដ្ឋខ្មែរ និងដោយសារការទម្លាក់គ្រាប់បែករបស់កងទ័ពអាមេរិក នៅក្នុងសម័យនៃការវាយប្រយុទ្ធគ្នានោះ។ សារទូរលេខផ្លូវទូតទាំងនោះគ្រាន់តែជាការផ្ដល់នូវទស្សនាទានមួយផ្នែក និងមានលក្ខណៈលម្អៀងនៃព្រឹត្តិការណ៍ដែលបានកើតឡើងក្នុងពេលមានជម្លោះប្រដាប់អាវុធនោះ។

១១. ដោយឡែក ប្រភពផ្ដល់ព័ត៌មានដែលត្រូវបានប្រើប្រាស់ដោយស្ថានទូតសហរដ្ឋអាមេរិកនៅកម្ពុជា និងដោយរដ្ឋមន្ត្រីការបរទេសអាមេរិក ដើម្បីធ្វើសេចក្ដីរាយការណ៍ក្នុងសារទូរលេខផ្លូវទូតរបស់ខ្លួនពុំត្រូវបានគេស្គាល់ និងមានលក្ខណៈលម្អៀងទៅរកសហរដ្ឋអាមេរិក។ សារទូរលេខភាគច្រើនពុំបានបញ្ជាក់ឈ្មោះ និងអត្តសញ្ញាណនៃប្រភពដែលបានផ្ដល់ព័ត៌មាន។ ព័ត៌មានទាំងនោះហាក់ដូចជាទទួលបានមកអំពី "ការដំណាលប្រាប់" អំពីសំណាក់បុគ្គលនានាដែលគេពុំស្គាល់អត្តសញ្ញាណ[16]។ មានប្រភពមួយចំនួនមានលក្ខណៈជាពាក្យចចាមអារ៉ាម ដែលមិនអាចយកជាការបាន[17]។ ប្រភព

---

[15] សូមមើលឯកសារ **E282.1.1** កថាខណ្ឌ ១០។

[16] ឧទាហរណ៍ សូមមើល៖ ឯកសារ **E282.1.2** កថាខណ្ឌ ៤៖ *"ប្រភពជាច្រើនប្រាប់យើងថា ពួកគេត្រូវបានបំបែកជាក្រុមយុវជន និងក្រុមយុវនារីក្លាមៗ ហើយបញ្ជូនទៅត្រើយខាងកើតទន្លេមេគង្គ ដើម្បីទទួលការអប់រំមនោគមវិជ្ជា និងយោធា*[...]"។

[17] សូមមើលឯកសារ **E282.1** កថាខណ្ឌ ៣៖ *"មានពាក្យចចាមអារាមផ្សព្វផ្សាយនៅកំពង់ចាមថា គ្រួសារគ្រូបង្រៀនបឋមសិក្សាចំនួន ៤០ គ្រួសារ ត្រូវបានបញ្ជូនទៅសម្លាប់នៅក្បែរភូមិ (Phum) និងរោងគោ (Rokor)។ (បច្ចុប្បន្ននេះ មិនមានការបញ្ជាក់ណាមួយអំពីរឿងនេះទេ)"*។

តែមួយគត់ដែលគេស្គាល់អត្តសញ្ញាណបាន គឺប្រភពព័ត៌មានដែលបានមកពីមេបញ្ជាការ ឬបានមកអំពីកងទ័ពសាធារណរដ្ឋខ្មែរ[18] ដែលប្រភពព័ត៌មានទាំងនេះពុំមានលក្ខណៈប្រាកដប្រជា ផងទេ។

១២. រាល់ព័ត៌មានទាក់ទងនឹងការចោទប្រកាន់អំពីការសម្លាប់កងទ័ព និងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ បានមកអំពីប្រភពពុំស្គាល់។ សារទូរលេខផ្លូវទូតមួយដែលផ្ញើចេញមកពីក្រសួងការបរទេសសហរដ្ឋអាមេរិក បានបង្ហាញអំពីភាពស្រពិចស្រពិលនៃព័ត៌មានដែលទទួលបាន ដោយហេតុថា សារទូរលេខនោះបានបញ្ជាក់យ៉ាងច្បាស់ថា ប្រភពផ្តល់ព័ត៌មាន និងភាពដែលគួរឱ្យជឿជាក់បាននៃព័ត៌មានទាំងនោះពុំត្រូវបានគេបង្ហាញឡើយ[19]។

១៣. ជាក់ស្តែង ព័ត៌មានដែលទទួលបានអំពីសារទូរលេខទាំងនេះ លើកលែងតែសារទូរលេខចំនួន៤ចេញ[20] ត្រូវបានប្រមូលដោយបុគ្គលិកស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅភ្នំពេញ។ នៅក្នុងសារទូរលេខទាំងនោះ ស្ថានទូតអាមេរិកបានបញ្ជាក់ថា ខ្លួនមិនត្រឹមតែពុំទទួលបាននូវតួលេខពិតប្រាកដនោះទេ ប៉ុន្តែថែមទាំងមិនអាចផ្ទៀងផ្ទាត់អំពីភាពប្រាកដប្រជានៃព័ត៌មានថែមទៀតផង[21]។

១៤. ផ្អែកលើខ្លឹមសារនៃសារទូរលេខទាំងនេះ យើងអាចវាយតម្លៃបានថា ព័ត៌មានដែលទទួលបាននាសម័យនោះ មានលក្ខណៈមិនអាចឱ្យយើងផ្ទៀងផ្ទាត់បាន ហេតុដូច្នេះ អ្វីដែលសហព្រះរាជអាជ្ញាមានបំណងលើកយកមកបង្ហាញដោយផ្អែកលើព័ត៌មានដែលផ្តល់តាមរយៈសារទូរលេខផ្លូវទូតទាំងនេះ តួយ៉ាងដូចជាការជម្លៀសប្រជាជនកម្ពុជាដោយបង្ខំ ការប្រព្រឹត្តមកលើប្រជាជននៅតាមទីក្រុង និងទីប្រជុំជននានា ដូចជាសត្រូវ និងការកាប់សម្លាប់មន្ត្រី និងយោធានៃរបបសាធារណរដ្ឋខ្មែរ ពិតជាពុំមានមូលដ្ឋានភស្តុតាងជាក់ស្តែងឡើយ។ ដូច្នេះ មេធាវីការពារក្តីសូមស្នើដល់អង្គជំនុំជម្រះ

---

[18] ឧទាហរណ៍ សូមមើល៖ ឯកសារ **E282.1.1** កថាខណ្ឌ ២ កថាខណ្ឌ ៩, ឯកសារ **E282.1.2** កថាខណ្ឌ ៣។

[19] ឯកសារ **E282.1.26** កថាខណ្ឌ ១។

[20] សារទូរលេខចំនួនបួនមិនមែនផ្ញើចេញពីស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅទីក្រុងភ្នំពេញនោះទេ៖ ឯកសារ **E282.1.7**, **E282.1.14**, **E282.1.17** និង **E282.1.26**។

[21] ឧទាហរណ៍ សូមមើល៖ ឯកសារ **E282.1.2** កថាខណ្ឌ ៣។

សាលាដំបូងមេត្តាប្រកាសថា សារទូរលេខផ្លូវទូតទាំងនោះមិនអាចទទួលយកបាន ដោយផ្អែកលើវិធាន ៨៧.៣ (គ)។

## ៣. សារទូរលេខទាំងនោះធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់មេធាវីការពារក្តីនាដំណាក់កាលនេះនៃការជំនុំជម្រះ

១៥. ការទទួលយកនាដំណាក់កាលនេះ នូវសារទូរលេខផ្លូវទូតដែលជាឯកសារភ័ស្តុតាងដាក់បន្ទុក ហើយដែលគេមិនអាចពិភាក្សាឱ្យបានត្រឹមត្រូវលើកម្មវត្ថុរបស់វានោះ នឹងធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិរបស់មេធាវីការពារក្តី។ សហព្រះរាជអាជ្ញាធ្លាប់បានធ្វើការតាំងសំណួរយ៉ាងរីករាយទៅលើសាក្សីទាំងឡាយដែលបានចូលខ្លួនមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ពាក់ព័ន្ធនឹងអង្គហេតុខាងលើនេះ ក្នុងក្របខណ្ឌនៃការបង្ហាញអំពីបរិបទប្រវត្តិសាស្ត្រ។ សារទូរលេខទាំងនេះត្រូវបានគេទម្លាយជាសាធារណៈតាំងពីប៉ុន្មានឆ្នាំមកហើយ ហើយក្នុងក្របខណ្ឌនៃការស៊ើបអង្កេតស្វែងរកពិរុទ្ធភាពរបស់ខ្លួន សហព្រះរាជអាជ្ញាគួរតែត្រូវបានពិនិត្យលើឯកសារទាំងនេះ ប្រសិនណាជាសហព្រះរាជអាជ្ញាយល់ឃើញថាវាមានសារៈ សំខាន់ខ្លាំងដល់សារណាចោទប្រកាន់របស់ខ្លួននោះ។ ប៉ុន្តែសហព្រះរាជអាជ្ញាពុំបានធ្វើឡើយ។

១៦. អយ្យការក៏មានឱកាសផងដែរក្នុងការស្នើសុំដល់អង្គជំនុំជម្រះឱ្យកោះហៅសាក្សីដែលពាក់ព័ន្ធនឹងប្រធានបទច្បាស់លាស់មួយនេះ។ មេធាវីការពារក្តីអាចធ្វើការតាំងសំណួរបកទៅវិញបាន។ ជំនួសឱ្យការធ្វើដូច្នេះ សហព្រះរាជអាជ្ញាបែរជាស្នើសុំឱ្យមានការទទួលយកដោយយឺតយ៉ាវ នូវសារទូរលេខផ្លូវទូតទាំងនេះ ទាំងស្រពិចស្រពិល ដែលធ្វើឱ្យមេធាវីការពារក្តីមិនអាចមានលទ្ធភាពក្នុងការឆ្លើយតបទៅនឹងការចោទប្រកាន់ដែលបានលើកឡើង។

## ៤. សារទូរលេខផ្លូវទូតដែលពុំមានភាពសមស្រប

១៧. មេធាវីការពារក្តីក ខៀវ សំផន សូមធ្វើការជំទាស់ទៅនឹងការដាក់បញ្ចូលសារទូរលេខផ្លូវទូតមួយចំនួន ដោយហេតុថាសារទូរលេខទាំងនោះពុំមានភាពសមស្របសម្រាប់ឱ្យមានការដាក់បញ្ចូល។

១៨. សារទូរលេខផ្លូវទូតលេខ E282.1.7 ពុំមានភាពសមស្របដែលអាចដាក់បញ្ចូលទៅក្នុងសំណុំរឿងបានឡើយ ដោយផ្អែកតាមវិធាន ៨៤.៣ (ក) ដោយហេតុថាសារទូរលេខនេះគ្រាន់តែបញ្ជាក់ថាមានរូបថតបង្ហាញអំពីព្រឹត្តិការណ៍ ប៉ុន្តែជាក់ស្តែងពុំបានភ្ជាប់រូបថតណាមួយទៅនឹងសារទូរលេខនោះឡើយ។

១៩. បើយោងតាមសហព្រះរាជអាជ្ញា សារទូរលេខមួយចំនួនធំដែលនឹងត្រូវបានដាក់បញ្ចូលដើម្បីបង្ហាញថាលោក ខៀវ សំផន បានវិលត្រលប់មកប្រទេសកម្ពុជាក្នុងខែ មិថុនា ឆ្នាំ ១៩៧៤ ដើម្បីចូលរួមកិច្ចប្រជុំរបស់គណៈមជ្ឈិមបក្ស ដែលត្រូវបានចោទប្រកាន់ថាជាកិច្ចប្រជុំដើម្បីពិភាក្សា និងចេញសម្រេចពាក់ព័ន្ធនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ[22]។

២០. មេធាវីការពារក្តីកត់សម្គាល់ឃើញថា ពុំមានព័ត៌មានណាមួយនៅក្នុងសារទូរលេខតាមផ្លូវទូតទាំងនេះ ដែលបញ្ជាក់អំពីការវិលត្រលប់របស់លោក ខៀវ សំផន មកក្នុងប្រទេសកម្ពុជា នាខែ មិថុនា ឆ្នាំ ១៩៧៤ និងបញ្ជាក់ថាលោកបានមានវត្តមាន និងបានចូលរួមក្នុងកិច្ចប្រជុំនានារបស់គណៈមជ្ឈិមបក្សនោះទេ។ ផ្ទុយអំពីការបង្ហាញរបស់សហព្រះរាជអាជ្ញា សារទូរលេខផ្លូវទូតទាំងនេះពុំមែនជាឯកសារភ័ស្តុតាងដែលបង្ហាញថា ជនជាប់ចោទមានវត្តមាននៅក្នុងកិច្ចប្រជុំរបស់គណៈមជ្ឈិមបក្សនាខែ មិថុនា ឆ្នាំ ១៩៧៤ ឡើយ។ សារទូរលេខទាំងនោះពុំបាននិយាយពាក់ព័ន្ធនឹងកិច្ចប្រជុំរបស់គណៈមជ្ឈិមបក្សឡើយ ហេតុដូច្នេះសារទូរលេខទាំងនោះពុំមានភាពសមស្របពាក់ព័ន្ធនឹងការចោទប្រកាន់ដែលថាជនជាប់ចោទបានចូលរួមក្នុងកិច្ចប្រជុំរបស់គណៈមជ្ឈិមបក្ស ឬពាក់ព័ន្ធនឹងខ្លឹមសារនៃកិច្ចប្រជុំទាំងនោះឡើយ ដោយផ្អែកតាមវិធាន ៨៧-៣ (ក) នោះ។

២១. **ហេតុដូច្នេះ** មេធាវីការពារក្តីលោក ខៀវ សំផន សូមស្នើដល់អង្គជំនុំជម្រះសាលាដំបូងមេត្តា៖

- **បដិសេធចោល**សំណើសុំរបស់សហព្រះរាជអាជ្ញាដែលស្នើឲ្យដាក់បញ្ចូលទៅក្នុងសំណុំរឿងនូវសារទូរលេខតាមផ្លូវទូតចំនួន ២៦ សារទូរលេខ ដូចដែលបានលើកឡើងក្នុងសំណើសុំរបស់ខ្លួនចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៣។

---

[22] សំណើសុំ កថាខណ្ឌ ១១។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន | ទីក្រុងភ្នំពេញ | |
| | មេធាវី Anta GUISSÉ | ទីក្រុងប៉ារីស | |
| | មេធាវី Arthur VERCKEN | ទីក្រុងប៉ារីស | |
| | មេធាវី Jacques VERGÈS | ទីក្រុងប៉ារីស | |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |